# អរិយធម៌ទីម៉ូរីត (Timurids civilization)

ទីម៉ូរីត គឺជាអរិយធម៌ និងជាអាណាចក្រដ៏ធំមួយ ដែលខ្លាំងក្លាបំផុតនៅក្នុងតំបន់អាស៊ីកណ្ដាល។ អរិយធម៌មួយនេះគឺកើតចេញពីកុលសម្ព័ន្ធមួយដែលហៅថា Turko-Mongol ស្ថិតនៅក្នុងតំបន់ Transoxiana។ សព្វថ្ងៃជាតំបន់ដែលស្ថិតនៅក្នុងបណ្ដាប្រទេសដូចជា អ៊ូសបេគីស្ថាន តាជីគីស្ថាន កាហ្សាក់ស្ថានខាងត្បូង និងកៀហ្ស៊ីស៊ីស្ថានខាងត្បូង។[១]

អរិយធម៌ទីម៉ូរីតនេះ បានក្លាយជាអាណាចក្រដ៏ធំ ដែលមានផ្ទៃដីគ្រប់គ្រងស្ទើតែទាំងស្រុងនៃអាស៊ីកណ្ដាល និងគ្រប់គ្រងផ្នែកខ្លះនៃប្រទេសរូស៊ី និងឥណ្ឌាដែរ។[២] នៅអំឡុងដើមស.វ.ទី ១៤នៃគ.ស. អាណាចក្រទីមេរីត ចាប់ផ្ដើការពង្រីកទឹកដី ដោយធ្វើសង្គ្រាមទៅលើបណ្ដាប្រទេសក្បែរៗខាង រួមមានចិន ស៊ីរី រហូតដល់អ៊ីរ៉ាក់ អ៊ីរ៉ង់ជាដើម។[៣]

រាជធានីនៃអាណាចក្រនេះមានឈ្មោះថា Samarqand ដែលសព្វថ្ងៃស្ថិតនៅក្នុងប្រទេសអ៊ូសបេគីស្ថាន។ Samarqand គឺទីក្រុងដ៏សំខាន់មួយក្នុងចំណោមបណ្ដាទីក្រុងផ្សេងៗទៀតនៅក្នុងអាណាចក្រនេះ និងជាតំបន់ដ៏ចំណាស់បំផុតនៅក្នុងតំបន់អាស៊ីកណ្ដាលដែរ។[៤] នៅទីនេះ គឺមានសំណង់ស្ថាបត្យកម្មសំខាន់ៗជាច្រើន ដែលបង្ហាញអំពីរចនាបថ សិល្បៈនៃអរិយធម៌ទីម៉ូរីត។ សំណង់ស្ថាបត្យកម្មទាំងនោះ គឺភាគច្រើនទទួលឥទ្ធិពល ពីសិល្បៈវប្បធម៌ អារ៉ាប់ (Ottoman)។

ការទទួលឥទ្ធិពល គឺនៅពេលដែលអរិយធម៌ទូគស្ថិតនៅក្រោមសម័យកាលអូតូម៉ង់។ ឥទ្ធិលនៃសិល្បៈ ស្ថាបត្យកម្ម នៃអរិយធម៌ទីម៉ូរីត គឺលាតសន្ធឹងពីតំបន់ Anatolia[៥] រហូតដល់ប្រទេសឥណ្ឌា។[៦]

---

[១] https://www.metmuseum.org/toah/hd/timu/hd_timu.htm

[២] ibid

[៣] ibid

[៤] https://www.britannica.com/place/Samarkand-Uzbekistan

[៥] https://www.britannica.com/place/Anatolia

[៦] https://www.metmuseum.org/toah/hd/timu/hd_timu.htm

អត្ថបទដោយ៖ អេង តុលា

សំណង់ស្ថាបត្យកម្មសំខាន់ជាងគេនៅក្នុងអរិយធម៌ និងអាណាចក្រទីម៉ូរីត គឺជាសំណង់ព្រះវិហារបែបសាសនាអាភ៉ប់ ដែលហៅថា Mosque។ ព្រះវិហារក្នុងអរិយធម៌នេះកសាងមានដំបូលខ្ពស់ៗ មានទំហំធំ ដែលហៅថា large bulbous double domes[៧] និងរួមផ្សំជាមួយនឹងសិល្បៈគំនូរនៅលើវិហារដ៏សំបូរបែប ដែលឃើញមាននៅបណ្តាព្រះវិហារនៅក្នុងប្រទេស អ៊ូសបេគីស្ថាន និងតាជីគីស្ថាន។

ចំពោះគំនូរទាំងនោះភាគច្រើន គឺគួរទាក់ទង នឹងការគោរពប្រតិបត្តិអំពីសាសនាអ៊ីស្លាម ជាមួយនឹងការឱ្យតម្លៃនៃស្រ្តីផងដែរ។ គួរបញ្ជាក់ដែរថា ជនជាតិទីមើរីតនេះ គឺពូកែខាងធ្វើសង្គ្រាម។

អរិយធម៌ និងអាណាចក្រទីម៉ូរីត ត្រូវបានដួលរលំនៅអំឡុងពាក់កណ្ដាលស.វ.ទី១៦។ រាល់ទន្និន័យទាំងអស់ដែលបានបង្ហាញខាងលើ និងតាមរយៈសំណង់ស្ថាបត្យកម្ម សិល្បៈដែលបានបន្សល់ពីអរិយធម៌នេះ បានបង្ហាញថា អរិយធម៌ទីម៉ូរីតត្រូវបានគេស្គាល់ថាជាអរិយធម៌ដែលមានឥទ្ធិពល ខ្លាំងក្លានៅក្នុងអាស៊ីកណ្ដាលដែលមានអាយុកាល ចាប់ពីឆ្នាំ១៣៧០នៃគ.ស. និងត្រូវបានដួលរលំនៅឆ្នាំ១៥០៧នៃគ.ស. ពោលគឺមានរយៈពេលត្រឹមតែ២ស.វ.តែប៉ុណ្ណោះ។ យើងក៏អាចដឹងអំពីទំនាក់ទំនងរវាងអរិយធម៌ដែលស្ថិតនៅក្នុងតំបន់អាស៊ីកណ្ដាលជាមួយនឹងតំបន់មជ្ឈឹមបូព៌ាជាដើម តាមរយៈឥទ្ធិពល សិល្បៈ និងវប្បធម៌ផ្សេងៗជាដើម។

[៧] https://www.metmuseum.org/toah/hd/timu/hd_timu.htm

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីនៃអរិយធម៌ ឬអាណាចក្រទីម៉ូរីត ( Map of the civilization Timurid)

ប្រភព៖ https://medieval-islamic-history.com



រូបលេខ២៖ ទីក្រុង Samarqand

ប្រភព៖ https://www.unchartedbackpacker.com

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៣៖ ព្រះវិហារ ក្នុងអរិយធម៌ ទីម៉ូរីត

ប្រភព៖https://whc.unesco.org



រូបលេខ២៤៖ ស៊ុមទ្វារ

ប្រភព៖ https://www.metmuseum.org/

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥៖ គំនូរ និងអក្សរ នៃអរិយធម៌ទីម៉ូរីត

ប្រភព៖ https://www.metmuseum.org/



រូបលេខ២៦៖ ចានគោម មកពីចិន ដែលឃើញមានក្នុងអរិយធម៌ទីម៉ូរីត

ប្រភព៖ https://www.metmuseum.org/

អត្ថបទដោយ៖ អេង តុលា

## ឯកសារយោង

https://www.metmuseum.org/toah/hd/timu/hd_timu.htm

https://www.britannica.com/place/Samarkand-Uzbekistan

https://www.britannica.com/place/Anatolia

អត្ថបទដោយ៖ អេង តុលា